ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២២៤ ស្តីពី ការតែងតាំងឯកឧត្តម **ឌិន សុខឃួន** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ ១០៣៣៩

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២២៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ ស៊ុនហ្សុង** (LIU SUNZHONG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន ១០៣៤០

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២២៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ាន គុក យឿន** (YAN KOCK YEUN) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតនៅខេត្តភីរ៉ាក់ ប្រទេសម៉ាឡេស៊ី ដោយប្តូរឈ្មោះជា **យ៉ាន យឿន** (YAN YEUN) ១០៣៤១

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២២៨ ស្តីពី ការតែងតាំងមន្ត្រីរាជការចំនួន ០៣ រូប ជាទីប្រឹក្សាអមក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១០៣៤២

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២២៩ ស្តីពី ការតែងតាំងឯកឧត្តម **អឿង សិរី** ជាទីប្រឹក្សាអមក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ១០៣៤៣

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣០ ស្តីពី ការតែងតាំងទីប្រឹក្សា និងអនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ចំនួន ០៣ រូប ១០៣៤៤

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣១ ស្តីពី ការតែងតាំងជំនួយការឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែន ចំនួន ០២ រូប ១០៣៤៥

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣២ ស្តីពី ការតែងតាំងឯកឧត្តម **ឆួង ឧត្តរា** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១០៣៤៦

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣៣ ស្តីពី ការតែងតាំងឯកឧត្តម **អ៊ឹង ប៊ុនហ៊ួច** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី ពុំទទួលប្រាក់បៀវត្សរ៍ ១០៣៤៧

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣៤ ស្តីពី ការបញ្ចប់មុខតំណែងសមាជិក នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មុខតំណែងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ចំនួន ០៦ រូប ១០៣៤៨

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ នៃសាលាខេត្តកោះកុង ចំនួន ១៤ រូប ១០៣៥០

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣៦ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **អាឡិចសាន់ឌ័រ អ៊ីគណាតូវ** (**Alexander Ignatov**) នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ១០៣៥១

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះសប្បុរសជន ចំនួន ០៦ រូប ១០៣៥២

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣៨ ស្តីពី ការតែងតាំងលោកជំទាវ **ជា ច័ន្ទទេវី** ជា ឧកញ៉ា ១០៣៥៣

១១-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៣៩ ស្តីពី ការតែងតាំងឯកឧត្តម **ទេព សាលីន** ជា ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៥ មានឋានៈស្មើ រដ្ឋលេខាធិការ ១០៣៥៤

១៥-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៤២ ស្តីពី ការតែងតាំងលោក **តៅ មុយលីម** ជា ឧកញ៉ា ១០៣៥៥

១៥-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៤៣ ស្តីពី ការតែងតាំង ទីប្រឹក្សា និងជំនួយការ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី ៥ ចំនួន ៣៤ រូប ១០៣៥៦

១៥-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៤៤ ស្តីពី ការតែងតាំងជំនួយការ ឯកឧត្តម **ច័ន្ទ សារុន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ចំនួន ០២ រូប ១០៣៥៩

## II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

២៥-១១-២០១៣ -អនុក្រឹត្យលេខ ៥៣៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦៣១,៣២ ហិកតា នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤០៨ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៣៦០

២៥-១១-២០១៣ -អនុក្រឹត្យលេខ ៥៤០ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៧៩៩,៥១ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩៤ គ្រួសារ និងរក្សាទុកមួយ ចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៣៦៩

២៥-១១-២០១៣ - អនុក្រឹត្យលេខ ៥៤១ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៦៧៨,២៦ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងនោះកាត់ចេញពី (១) កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២) កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សុវណ្ណវិរ៉ឡង់ (៣) កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វជូនណា ផ្លេនថេលសិន ខេមបូឌា លីមីធីត និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋ ២៧៦ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៣៧៦

២៥-១១-២០១៣ - អនុក្រឹត្យលេខ ៥៤២ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦៧៧ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣១៩ គ្រួសារ និងរក្សាទុកមួយ ចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៣៨៣

២៥-១១-២០១៣ - អនុក្រឹត្យលេខ ៥៤៣ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ២៤៤,១៧ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩២ គ្រួសារ និងរក្សាទុកមួយ ចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៣៩០

២៥-១១-២០១៣ - អនុក្រឹត្យលេខ ៥៤៤ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ២០៧,៩៥ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៣១ គ្រួសារ និងរក្សាទុកមួយ ចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៣៩៤

២៥-១១-២០១៣ - អនុក្រឹត្យលេខ ៥៤៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១០៣៩៨

២៨-១១-២០១៣- អនុក្រឹត្យលេខ ១១២៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៤០០

២៩-១១-២០១៣- អនុក្រឹត្យលេខ ១១២៩ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាន់ខ្ពស់ ១០៤០២

០២-១២-២០១៣- អនុក្រឹត្យលេខ ១១៣០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០៤០៣

០២-១២-២០១៣- អនុក្រឹត្យលេខ ១១៣១ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១០៤០៤

០២-១២-២០១៣- អនុក្រឹត្យលេខ ១១៣២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០៤០៦

០២-១២-២០១៣- អនុក្រឹត្យលេខ ១១៣៣ អនក្រ.តត ស្តីពី ការជូនមេដាយ ១០៤០៧

០៣-១២-២០១៣- អនុក្រឹត្យលេខ ១១៣៤ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១០៤០៨

០៣-១២-២០១៣- អនុក្រឹត្យលេខ ១១៣៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៤០៩

០៣-១២-២០១៣- អនុក្រឹត្យលេខ ១១៣៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១០៤១០

០៣-១២-២០១៣- អនុក្រឹត្យលេខ ១១៣៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ១០៤១១

០៤-១២-២០១៣- អនុក្រឹត្យលេខ ១១៣៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៤១២

០៤-១២-២០១៣ -អនុក្រឹត្យលេខ ១១៣៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៤១៣
០៤-១២-២០១៣ -អនុក្រឹត្យលេខ ១១៤០ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ១០៤១៤
០៥-១២-២០១៣ -អនុក្រឹត្យលេខ ១១៤១ អនក្រ.តត ស្តីពី ការតម្លើងឋានៈជូនមន្ត្រីរាជការ ១០៤១៦
០៥-១២-២០១៣ -អនុក្រឹត្យលេខ ១១៤២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ១០៤១៧
០៥-១២-២០១៣ -អនុក្រឹត្យលេខ ១១៤៣ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សា និងជំនួយការក្រសួងមហាផ្ទៃ ១០៤១៩

## ២-សេចក្តីសម្រេច

០៤-១២-២០១៣-សេចក្តីសម្រេចលេខ ៤៩ សសរ ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាសកម្មភាពជនពិការ ១០៤២២
០៦-១២-២០១៣-សេចក្តីសម្រេចលេខ ៥០ សសរ ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល រៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង នៃព្រះរាជាណាចក្រកម្ពុជា ១០៤២៥

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៦-១១-២០១៣-ប្រកាសលេខ ១០៩៧ សបហវ. ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៤២៨
០៦-១១-២០១៣-ប្រកាសលេខ ១០៩៩ សបហវ. ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៤៣០
០៦-១១-២០១៣-ប្រកាសលេខ ១១០០ សបហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៤៣២
០៦-១១-២០១៣-ប្រកាសលេខ ១១០១ សបហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៤៣៤
០៦-១១-២០១៣-ប្រកាសលេខ ១១០២ សបហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៤៣៦
០៦-១១-២០១៣-ប្រកាសលេខ ១១០៣ សបហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៤៣៨
០៦-១១-២០១៣-ប្រកាសលេខ ១១០៤ សបហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៤៤០
០៦-១១-២០១៣-ប្រកាសលេខ ១១០៥ សបហវ.អថ ស្តីពី ការបន្ថែមឥណទានថវិកាជូនក្រសួងធម្មការ និង សាសនា ១០៤៤៣

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

៣០-១០-២០១៣-ប្រកាសលេខ ៨៩៤ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន យីនហ្វេង (ខេមបូឌា) បង្កើតរោងចក្រ ផលិតអាល់កុល, ជីសរីរាង្គសមាស ១០៤៤៤
៣០-១០-២០១៣-ប្រកាសលេខ ៨៩៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កៅថេក ហ្គាមេន បង្កើតរោងចក្រផលិតសម្លៀកបំពាក់ ១០៤៤៨

៣០-១០-២០១៣-ប្រកាសលេខ ៨៩៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោល លិនិន នីតធីង ហ្វេកធើរី បង្កើតរោងចក្រផលិតសម្លៀកបំពាក់ (ចាក់) ១០៤៥៣
០៧-១១-២០១៣-ប្រកាសលេខ ៩០៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៉ូលីហ្សា (ខេមបូឌា) ហូម ថេកស្ថាយ បង្កើតរោងចក្រ ផលិតកម្រាលពូក ១០៤៥៧

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ឌិន សុខឃួន** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១៣១១. ១២៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ ១១៩៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៧៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ ស៊ុនហ្សុង** (LIU SUNZHONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៦៨ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣នស.១៣១១.១៧៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ: ១១៩០ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២២៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ាន គុក យឿន** (YAN KOCK YEUN) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៤៦ នៅខេត្តភីរ៉ាក់ (Perak) ប្រទេសម៉ាឡេស៊ី ដោយប្តូរឈ្មោះជា **យ៉ាន យឿន** (YAN YEUN)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស.១៣១១.១២៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១១៥៥ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងមន្ត្រីរាជការចំនួន ០៣ រូប ជាទីប្រឹក្សាអមក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៖

១. ឯកឧត្តម ស៊ុយ សាន បន្ថែមលើមុខងារបច្ចុប្បន្ន
២. ឯកឧត្តម ជួប សុកក្តិ
៣. ឯកឧត្តម ឯក រដ្ឋ

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពកស.១៣១១.១២៤២

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១១៩៣ស.ណ
**សំណៅដែលមានការធ្វើជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **អឿង សិរិៈ** ជាទីប្រឹក្សាអមក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹតនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
**នរោត្តម សីហមុនី**

៣៦ស.១៣១១.១២៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣

លេខ: ១២១៩ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៣០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងទីប្រឹក្សា និងអនុប្រធាន លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុក-កិច្ចការព្រំដែន ចំនួន ០៣ រូប ៖

១-ឯកឧត្តម **អ៊ុត សុភ្នា** ជាទីប្រឹក្សា ទទួលបន្ទុកបច្ចេកទេសផែនទី និងផលិតផែនទីព្រំដែន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម **កុយ ធិសុទ្ធ** ជាអនុប្រធាន ទទួលបន្ទុកអភិវឌ្ឍន៍តាមបណ្តោយព្រំដែន មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣-ឯកឧត្តម **ហាស់ ផល្លារិទ្ធ** ជាអនុប្រធាន ទទួលបន្ទុកដោះស្រាយបាតុភាពតាមបណ្តោយព្រំដែន មានឋានៈស្មើ អគ្គនាយក។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧. ១៣១១. ១២៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ ៦១៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៧១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងជំនួយការឯកឧត្តម **ទ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែន ចំនួន ០២ រូប ៖

| | |
|---|---|
| ១-ឯកឧត្តម **ខន ដានិត** | មានឋានៈស្មើ អគ្គនាយក |
| ២-លោកជំទាវ **ឃួត ពិសីពេជ្ជនី** | មានឋានៈស្មើ អគ្គនាយក។ |

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស. ១៣១១. ១២៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ ១១៨១ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/១១១៣/១២៣២

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ដួង ឆុន្នា** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.១៣១១.១២៤៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១១៧៩ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៣៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **អ៊ឹង ម៉ុនហ៊ុច** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី ពុំទទួលប្រាក់បៀវត្សរ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៤. ១៣១១. ១២៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១១៩៤ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

នស/រកត/១២១៣/១២៣៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/៩៥៦ ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរំសាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និងក្រុមប្រឹក្សាកំណែទម្រង់ផ្សេងទៀត ចំណុះឲ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បញ្ចប់មុខតំណែងសមាជិក នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មុខតំណែងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ៖

១- ឯកឧត្តម **លឹម ទាន់** សមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី
មានឋានៈស្មើ រដ្ឋលេខាធិការ

២- លោកជំទាវ **អ៊ូ ច័ឌី** អគ្គលេខាធិការរងអចិន្ត្រៃយ៍
មានឋានៈស្មើ អនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

| | |
|---|---|
| ៣- លោកជំទាវ **នន់ ភានី** | អគ្គលេខាធិការរង មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៤- ឯកឧត្តម **កែវ កុសល** | អគ្គលេខាធិការរង មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៥- ឯកឧត្តម **ហ៊ីយ ផាប់** | សមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានឋានៈស្មើ អគ្គនាយក |
| ៦- ឯកឧត្តម **ជា ផលរី** | អគ្គលេខាធិការរង មានឋានៈស្មើ អគ្គនាយក ។ |

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤. ១៣១១. ១២៤៤

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/១១១៣/១២៣៥

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រោសព្រះរាជទាន

ចំពោះ
មន្ត្រីរាជការ នៃសាលាខេត្តកោះកុងចំនួន ១៤រូប ដែលមានស្នាដៃល្អ
ក្នុងការចូលរួមកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-លោក **សាយ សុជាតិ**
២-លោក **ជុំ យុហឿន**
៣-លោក **អ៊ុច ឆូច**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-លោក **លឹម សាវាន់**
២-លោក **ម៉ឹម ផៃបួន**
៣-លោក **សិន យិន**
៤-លោកស្រី **ឈូក ម៉ារី**
៥-លោក **សេក សំអុល**

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-លោក **គង់ សុវណ្ណ**
២-លោក **ផន គីមកន**
៣-លោក **ឡុង ប៊ុណ្ណាត**
៤-លោក **យូ មី**
៥-លោក **យុត វ៉ាន់ដា**
៦-លោក **ឡៅ ប៊ុនខេង**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាវល.១៣១១.១២៤៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២២៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១៣**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ប្រោសព្រះរាជទាន**

**ចំពោះ**

**ឯកឧត្តម អាឡិចសាន់ដឺរ អ៊ីគណាតូវ** (Alexander Ignatov)

**នូវ**

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពកស.១៣១១.១២៥០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៣*

លេខៈ១២១៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៣៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រោសព្រះរាជទាន

## ចំពោះ

សប្បុរសជនចំនួន ០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ ធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅក្នុងខេត្តស្វាយរៀង

## នូវ

ក- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

លោកជំទាវ **ហួត នេងជូ**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

ឧកញ៉ា **ឡុង ណារិន**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-ព្រះតេជគុណព្រះមហា **យូ តួច** ២-លោកស្រី **ចៅ ចំនួនណារ៉ា**

៣-លោក **ពៅ បូរណ** ៤-លោក **សាំង សុខា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៩. ១៣១១. ១២៥១

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១៧១៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា**

ត្រាស់បង្គាប់

តែងតាំង :

លោកជំទាវ ជា ច័ន្ទទេវី

ជា

ឧកញ៉ា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១៣១១. ១២៥២

លេខ:១២៣០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៣៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ឆេត សាលីន** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១៣១១. ១២៥៣

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ: ១២២៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៨៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា)

ត្រាស់បង្គាប់

តែងតាំង :

លោក កៅ មួយលីម

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.១៣១១.១២៥៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៥ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដាឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៥ នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៥
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង:

ក- ទីប្រឹក្សា

| | |
|---|---|
| ១- ឯកឧត្តម **ឡាន់ ឆន** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ២- ឯកឧត្តម **ឆា ច័ន្ទលីដា** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ៣- ឯកឧត្តម **សំរិទ្ធ សារុន** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ៤- ឯកឧត្តម **គឹម ហេង** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ៥- ឯកឧត្តម **ប៉ាង វ៉ាន់ថា** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ៦- ឯកឧត្តម **ពេជ្រ កៅ** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ៧- លោកជំទាវ **សួន ស៊ីណា** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៨- ឯកឧត្តម **ម៉ែន សុចិត្រ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៩- ឯកឧត្តម **នូច ប៉ោលីន** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១០- ឯកឧត្តម **សូ ផាណារ៉ូ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១១- ឯកឧត្តម **ហង់ ទូច** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១២- ឯកឧត្តម **ហង្ស ឆាំឆាន** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១៣- ឯកឧត្តម **ម៉ៅ ញ៉ូ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១៤- ឯកឧត្តម **អុប សូភី** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១៥- ឯកឧត្តម **ហ៊ូ វាសនា** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១៦- ឯកឧត្តម **នូ នីម** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១៧- ឯកឧត្តម **ស៊ឹម តែ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១៨- ឯកឧត្តម **លី ឡេង** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

១៩- ឯកឧត្តម **ឡុង ឆាម** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២០- ឯកឧត្តម **សេង ឈួន** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២១- ឯកឧត្តម **ស៊ិន សម្ផល្ល** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២២- ឯកឧត្តម **ឡុញ វណ្ណៈ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២៣- ឯកឧត្តម **កែវ វណ្ណៈ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២៤- ឯកឧត្តម **ហែម ហាន** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២៥- ឯកឧត្តម **ទន្លាប់ ឈុន** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២៦- ឯកឧត្តម **សុខ ត្រេះ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២៧- ឯកឧត្តម **គង់ ឈឹម** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | |
|---|---|
| ២៨- ឯកឧត្តម **ជឹម លាង** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។ |
| ២៩-ឯកឧត្តម **សោម ចាន់ដារ៉ុង** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។ |
| ៣០-ឯកឧត្តម **សំ សារ៉េន** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ៣១-ឯកឧត្តម **អេក ឃាង** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ៣២-ឯកឧត្តម **នុត មុនី** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។ |

**ខ- ជំនួយការ**

| | |
|---|---|
| ១- ឯកឧត្តម **សំ សារ៉ាក់** | ជាជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ២- ឯកឧត្តម **គាំ សុខាន់** | ជាជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន។ |

**មាត្រា ២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេច តាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១១១៣.១២៥៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២២៨ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងជាជំនួយការឯកឧត្តម **ចំនួ សារុន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ចំនួន ០២រូប ៖

១. លោក **ម៉ុង ណារិត** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

២. លោក **ប្រាក់ ចាន់មុនីជា** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ជ.រ.ល. ១៣១១.១២៥៥

លេខ:១២៣៧ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៦៣១,៣២ហិកតា នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៤០៨គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៨៨១អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៦៣១,៣២ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៦២១,១៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ១០,១៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិដូនទិព្វ ឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី ១ ទី ២ និងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៤០៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិដូនទិព្វ ឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥. ខែវិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*


ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ.......... ចុះថ្ងៃទី.......ខែ........ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំ ៦៣១,៣២ហិកតា នៅស្រុកថ្ពង
ខេត្តកំពង់ស្ពឺ ចេញពីដីតំបន់ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៤០៨គ្រួសារ
និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ
តារាងចំណុចកូអរដោនេ
សញ្ញាសំគាល់
ភូមិ
សាលាឃុំ
សាលាស្រុក
ស្ទឹង/អូរមានទឹកជាប្រចាំ
ស្ទឹង/អូរមានទឹកនៅរដូវវស្សា
ប្រឡាយ
ផ្លូវកៅស៊ូ
ផ្លូវក្រួសក្រហម ឬ ក្រាលថ្ម
ផ្លូវរទេះ ឬ ផ្លូវដើរ
ព្រំប្រទល់រាជធានី ខេត្ត
ព្រំប្រទល់ក្រុង ស្រុក ខណ្ឌ
ព្រំប្រទល់ឃុំ សង្កាត់
ក្បាលដីដែលបានវាស់វែង
ព្រំដីស្នើសុំកាត់ចេញពីព្រៃឈើឆ្នាំ២០០២
មាត្រដ្ឋាន 1:15,000
Meters
Coordinate System : UTM , Zone : 48N
Horizontal Datum : WGS_84 , Grid : 400m
ផែនទីស្រុកថ្ពង
ខេត្តកំពង់ឆ្នាំង
ស្រុកសំរោងទង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៧៥៩,៥១ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីតំបន់ព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩៤គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៤៧១ អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៧៥៩,៥១ ហិកតា ចេញពីដីតម្រូបព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៧១៥,៨៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែងនិងដីទំហំ ៤៣,៦៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិខ្នងភូមិ ឃុំព្រះខែ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី ១ និងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣៩៤គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិខ្នងភូមិ ឃុំព្រះខែ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៤១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៦៧៨,២៦ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងនោះ កាត់ចេញពី (១) កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២) កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សុវណ្ណាវិវឌ្ឍន៍ (៣) កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វូនណាផ្លែនថេលសិន ខេមបូឌា លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៦គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៤៧៦អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ី សាគុណ** អត្តលេខ ០១៧១ ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ចំណាយអស់ថវិកាចំនួន **៤៣.៧៥០ដុល្លារ**

២-ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ុន ថាវណ្ណា** អត្តលេខ ០១០១៦ អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ចំណាយអស់ថវិកាចំនួន **៣០.០៥០ដុល្លារ**

៣-លោកវរសេនីយ៍ឯក **ទូ ហាក់** អត្តលេខ ០៩៥៤០ អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក ចំណាយអស់ថវិកាចំនួន **១៧.៧៥០ដុល្លារ**

៤-លោកវរសេនីយ៍ទោ **ស៊ីវ សារ៉ាពេជ្រ** អត្តលេខ **៦៤៧៧** ជំនួយការឯកឧត្តមប្រធាននាយកដ្ឋានកណ្តាល ចំណាយអស់ថវិកាចំនួន **១០.៥២៥ដុល្លារ** ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៣៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយ សហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ~**

ត្រូវបានបំពាក់មេដាយ **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោកប្រធាន និងលោកអគ្គលេខាធិការគណៈកម្មាធិការបក្ស បណ្ឌិត្យសភានាយនគរបាលខេត្តយូណាន ចំនួន ០២ នាក់ នៃសាធារណៈរដ្ឋប្រជាមានិតចិន ដែលបានខិតខំប្រឹងប្រែងក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរកងកម្លាំងនគរបាលជាតិកម្ពុជា។

១-**MR. GUO BAO** ប្រធានបណ្ឌិត្យសភានាយនគរបាលខេត្តយូណាន(YPOA) នៃសាធារណៈរដ្ឋប្រជាមានិតចិន ស្នងការនគរបាលថ្នាក់លេខ១

២-**MR. DU MIN** អគ្គលេខាធិការគណៈកម្មាធិការបក្ស បណ្ឌិត្យសភានាយនគរបាលខេត្តយូណាន នៃសាធារណៈរដ្ឋប្រជាមានិតចិន ស្នងការនគរបាលថ្នាក់លេខ១

**មាត្រា ២ ~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា១ និងមាត្រា២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៧៥-អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយ មុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនបណ្ឌិត្យសភានាយនគរបាលខេត្តយុណាន នៃសាធារណៈរដ្ឋប្រជាមានិតចិន ដែលបានខិតខំប្រឹងប្រែងផ្លាស់ប្តូរមន្ត្រីនគរបាលនៃបណ្ឌិត្យសភានគរបាលទាំងពីរ ដើម្បីដកស្រង់នូវបទពិសោធន៍ និងចំណេះដឹងថ្មីៗអោយទទួលបានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរកងកម្លាំងនគរបាលជាតិ ហើយថ្មីៗនេះបណ្ឌិត្យ សភានាយនគរបាលខេត្តយូណាន បានផ្តល់នូវអំណោយ ជាកុំព្យូទ័រលើតុ ចំនួន ៥០ គ្រឿង ថែមទៀត។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ ឆ្នាំ ២០១៣
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ទិបឌិន្ឌ** ជូនសប្បុរសជននិងនាយទាហាន ចំនួន០២ រូប ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការជាមួយតំបន់ប្រតិបត្តិការសឹករងតាកែវ កន្លងមក ដូចមានរាយនាមខាងក្រោម :-

១- លោក **ឡេ ថាន់ខឺយ** LE THANN KHEUY ទីប្រឹក្សាគណៈបញ្ជាការយោធា ខេត្តអានយ៉ាង

២- វរសេនីយ៍ឯកបំរុង **វៀង តឺនតឹង** VEANG TEUN TOENG អនុប្រធានសេនាធិការយោធា ខេត្តអានយ៉ាង

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៣៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងលោកស្រី **ស៊ សើរ** ជាអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាចក្រថៃឡង់ដ៍ ។

**មាត្រា ២** : ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ១០៤៥ អនក្រ.តត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១១៣៧ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ចំនួន ០៣គ្រឿង ជូនមន្ត្រីអនុវត្តគម្រោង និងសប្បុរសជន ចំនួន ០៣រូប ដែលបានជួយសាងសង់ភូមិកុមារ អេស អូ អេស ក្រចេះ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក | ជុន ជា | នាយកភូមិកុមារ អេស អូ អេស កម្ពុជា |
| ២- | លោក | ប៊ី ជា | អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ |
| ៣- | លោកស្រី | តែ ម៉េងគៀង | សប្បុរសជន |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១១៣៩ អនក្រ.បក**

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**សម្រេច**

**មាត្រា ១.-**

បំពាក់ មេដាយមាសការងារ ចំនួន ០៨គ្រឿង ជូនមន្ត្រីអនុវត្តគម្រោង ចំនួន ០៨រូប ដែលមានស្នាដៃល្អ ក្នុងការជួយសាងសង់ភូមិកុមារ អេស អូ អេស ក្រចេះ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- | លោក | សូ ចំន្ទកុសុម | នាយកភូមិកុមារ អេស អូ អេស សៀមរាប |
| ២- | លោក | ខួន សុខគ្រី | អនុប្រធានរដ្ឋបាលស្នំកូនអន្តរប្រទេស |
| ៣- | លោក | មាស កុម្ភៈ | អនុប្រធានការិយាល័យ រដ្ឋបាលស្នំកូនអន្តរប្រទេស |
| ៤- | លោកស្រី | ឃីម សុប្រសើរ | អនុប្រធានការិយាល័យ រដ្ឋបាលស្នំកូនអន្តរប្រទេស |
| ៥- | លោក | ឡឹម ឌីម៉ង់ | អនុប្រធានការិយាល័យ រដ្ឋបាលស្នំកូនអន្តរប្រទេស |
| ៦- | លោក | ស៊ើន សូភី | អនុប្រធានការិយាល័យ រដ្ឋបាលស្នំកូនអន្តរប្រទេស |
| ៧- | កញ្ញា | អ៊ុយ សាទដី | មន្ត្រីរដ្ឋបាលស្នំកូន អន្តរប្រទេស |
| ៨- | កញ្ញា | សេក សុគំគ្រ | មន្ត្រីរដ្ឋបាលស្នំកូន អន្តរប្រទេស |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៨០.អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

# សម្រេច

**មាត្រា ១ .-** ត្រូវបានដាក់ លោក **ទិន សុខសាម៉ឺឌី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៨ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មុខតំណែងប្រធាននាយកដ្ឋានអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល ២ ឆ្នាំ គិតចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ រហូតដល់ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានៈជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើត ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រធានក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន

## សម្រេច

**មាត្រា ១:** តម្លើងឋានៈជូនសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដូចខាងក្រោម ៖

១-កញ្ញា ព្រាប កែវច័ន្ទមុនី មានឋានៈស្មើ អគ្គនាយករង

២-កញ្ញា ប៉ែន ច័ន្ទដារ៉ា មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៨ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៤៧ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពី

### ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

### សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ជូនសព

**ក. ដំឡើងឋានន្តរស័ក្តិថ្នាក់វរសេនីយ៍ឯក**

១- វរសេនីយ៍ទោ **ស៊ុក គឹមហាន** អត្តលេខ ០០១៥៣០ នាយរងការិយាល័យធានា នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

២- វរសេនីយ៍ទោ **លី គឹមពិសិដ្ឋ** អត្តលេខ ០១២៨៣៣ នាយរងការិយាល័យសារធាតុគីមីវិទ្យាស្ថាន ស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

៣- វរសេនីយ៍ទោ **កើត ឆន** អត្តលេខ ០១៩០៨៧ នាយផ្នែកអប់រំចិត្តសាស្ត្រ មជ្ឈមណ្ឌល ៣១៧ គួលេន

៤- វរសេនីយ៍ទោ **កៅ សិទ្ធ** អត្តលេខ ០១០០៤០ មេបញ្ជាការរង កងពលតូច អន្តរាគមន៍លេខ៤ កងពលធំអន្តរាគមន៍លេខ២ អគ្គបញ្ជាការដ្ឋាន

**ខ.ដំឡើងឋានន្តរស័ក្តិថ្នាក់វរនាវីឯក**

-វរនាវីទោ **សូ ចាន់** អត្តលេខ ០១៥០៦៩ នាយការិយាល័យឃោសនា ពត៌មាន មូលដ្ឋានសមុទ្រ បញ្ជាការដ្ឋានកងទ័ពជើងទឹក

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៥ ខែ ៨ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១៤៣ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងទីប្រឹក្សា និងជំនួយការក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងទីប្រឹក្សា និងជំនួយការក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម:

១-លោក **ឆូ ស៊ាងហៃ** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

២-លោក **ផាន់ ចាន់ធុល** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

៣-លោក **ឯម សាខន** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

៤-លោក **ខែក ម៉ាណូរ៉ា** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

៥-លោក **ជុំ យុហឿន** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

៦-លោក **អែល សយ** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

៧-លោក **ធុន ត្រី** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

៨-លោក **មាស ទុឡា** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

៩-លោក **ញាណ សារោ** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១០-លោក **ចោម បុផ្ផារិទ្ធ** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១១-លោក **កែវ សាមឿន** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១២-លោកស្រី **សា ចាន់ហ៊ាង** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១៣-លោក **កុយ សារឹម** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១៤-លោក **ង៉ោ ប្រុង** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១៥-លោក **ណៅ ណៃ** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១៦-លោក **សៀវ សុតថាវ** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១៧-លោក **អ៊ុក ហ៊ុន** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១៨-លោក **គីម សុផុន** ទីប្រឹក្សាក្រសួង មានឋានៈស្មើអគ្គនាយករង

១៩-លោក **ពៅ សុខន** ទីប្រឹក្សាក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២០-លោក **មឿន សាមន** ទីប្រឹក្សាក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២១-លោក **សយ សុខក្តិ** ទីប្រឹក្សាក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២២-លោក **ឈាវ ហ៊ី** ទីប្រឹក្សាក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២៣-លោក **រុន ចាន់ដារ៉ារិទ្ធ** ទីប្រឹក្សាក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២៤-លោក **សុខ សារ៉ាត** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២៥-លោក **ច្រឹង គីមស្រ៊ាន** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២៦-លោក **មូ សំបាន** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២៧-លោក **សំ សៀក** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២៨-លោក **សយ សុត** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

២៩-លោក **ជា ស្រួយ** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

៣០-លោក **ម៉ៅ ទីរៈ** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

៣១-លោក **អ៊ុយ ថន** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

៣២-លោក **ទួន សុខ** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

៣៣-លោក **អ៊ី សារ៉ាហាត់** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

៣៤-លោក **ស៊ឹម វណ្ណា** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

៣៥-លោក **អ៊ុំ សុខន** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

៣៦-លោក **ស្រេង ស្រ៊ាង** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

៣៧-លោក **តន់ ម៉ុនរឿង** ជំនួយការក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមាន ឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៩ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមប្រឹក្សាសកម្មភាពជនពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបញ្ចប់តួនាទី នៃការតែងតាំងសមាសភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ សេចក្តីសម្រេច លេខ ២៦សសរ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣។

**ប្រការ ២.-**

ត្រូវបានតែងតាំងសមាសភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការដូចខាងក្រោមៈ

- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស
- ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន
- ឯកឧត្តម **សែម សុខា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន
- ឯកឧត្តម **យឹម ឆ្នូរ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

- ឯកឧត្តម **ហេង តៃគ្រី** រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន
- ឯកឧត្តម **តេង សាវឿង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តម **នាង ផាត** រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន
- ឯកឧត្តម **យី វាសនា** ទីប្រឹក្សារាជរដ្ឋាភិបាល និងជានាយកប្រតិបត្តិមជ្ឈមណ្ឌលជាតិនៃជនពិការ អនុប្រធាន
- ឯកឧត្តម **ឯម ច័ន្ទមករា** អគ្គលេខាធិការនៃគ.ស.ជ សមាជិកអចិន្ត្រៃយ៍
- ឯកឧត្តម **ចាន់ រដ្ឋា** អគ្គលេខាធិការរងទទួលបន្ទុកកិច្ចសង្គ្រោះជនពិការដោយសារមីន នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន សមាជិក
- ឯកឧត្តម **ឆាន់ វឌ្ឍនះ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **ហ៊ាង ស៊ីណេ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា សមាជិក
- ឯកឧត្តម **ហាប់ អូម៉ាលី** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- ឯកឧត្តម **ម្ញូ សុភាព** អនុរដ្ឋលេខាធិការក្រសួងផែនការ សមាជិក
- ឯកឧត្តម **ហ៊ុយ សារ៉ាវុធ** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក
- ឯកឧត្តម **មាស ម៉ូនីកា** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- លោកជំទាវ **ឌិត្យ ច័ន្ទតារីន** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- លោកជំទាវ **ញ៉ែម មរកត** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក
- ឯកឧត្តម **ចាប ឫទ្ធី** អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- ឯកឧត្តម**គង់ កន្តារ៉ា** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
- ឯកឧត្តម **ឈឿន ម៉ុណ្ណារ័ត្ន** អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ សមាជិក
- ឯកឧត្តម **មាន សុភា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក
- ឯកឧត្តម **ម៉ាន សុគ្រី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ឯកឧត្តម **កែវ សុផល** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
- ឯកឧត្តម **ហោ សារុន** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
- លោកជំទាវ **ម៉ែន នារីសោភ័គ** អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា សមាជិក
- ឯកឧត្តម **រ៉ុត ឫទ្ធី** អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- ឯកឧត្តម **សាន វឌ្ឍនា** អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សមាជិក
- លោក **គុក ជួនថា** អគ្គនាយករងសភាពាណិជ្ជកម្មកម្ពុជា សមាជិក
- លោកស្រី **ម៉ក់ វណ្ណាស៊ីថា** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក
- លោក **ជាវ តាយ** អភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល សមាជិក
- លោកស្រី **ស៊ី វណ្ណថា** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ចាម សមាជិក
- លោកស្រី **ស៊ឹម ម៉ារី** អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង សមាជិក
- លោក **គឹម នៃហៀង** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប សមាជិក
- លោក **ស៊ុយ សេរិទ្ធ** អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ សមាជិក

| | | |
|---|---|---|
| - លោកស្រី **ភង សៅវ៉ែន** | អភិបាលរងនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| - លោក **សុខ លូ** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ធំ | សមាជិក |
| - លោក **ភាន រិទ្ធី** | អភិបាលរងនៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| - លោកស្រី **គង់ ស៊ីផា** | អភិបាលរងនៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| - លោក **សៀត គឹមលៀង** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| - លោកស្រី **កែវ សារឿន** | អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| - លោក **សឿ សុខណាល់** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| - លោក **កែវ សែន** | អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| - លោក **ស្រ៊ុន ស្រ៊ន់** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| - លោក **សាយ សុជាតិ** | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | សមាជិក |
| - លោកស្រី **ពៅ សុភាព** | អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង | សមាជិក |
| - លោក **ជាក់ ម៉េងហ៊ាង** | អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ | សមាជិក |
| - លោក **អៀង អូនលី** | អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| - លោក **អ៊ុង ឆាយ** | អភិបាលរងនៃគណៈអភិបាលខេត្តកែប | សមាជិក |
| - លោក **ថង គឿន** | អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| - លោក **អ៊ុំ ឡុង** | អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| - លោក **សាន វណ្ណា** | អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| - លោក **ស្វាយ សំអ៊ាង** | អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| - លោក **ងិន សៅរ័ត្ន** | នាយកប្រតិបត្តិអង្គការជនពិការកម្ពុជា | សមាជិក |
| - លោក **ម្លួន ម៉ៅ** | នាយកប្រតិបត្តិសមាគមនៃជនពិការភ្នែកកម្ពុជា | សមាជិក |
| - កញ្ញា **សុខ កុសល** | តំណាងអង្គការជេស៊ុសបម្រើនៅកម្ពុជា ក្រុមយុទ្ធនាការលុបបំបាត់មីន | សមាជិក |
| - កញ្ញា **ស្រេង វណ្ណី** | តំណាងអង្គការគ្រូសារថ្មី | សមាជិក |
| - លោក **មិនយ៉ាមីន ខៀន** | នាយកកម្មវិធីប្រចាំតំបន់អង្គការជនពិការអន្តរជាតិ | សមាជិក |

**ប្រការ ៣**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ ៨ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៥០ . សសរ**

# សេចក្តីសម្រេច

**ស្តីពី**

**ការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល រៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា**

*****

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងសេចក្តីសម្រេចលេខ ៤៨ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល រៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**ប្រការ ១.-**

កែសម្រួលសមាសភាពរបស់គណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល រៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង នៃព្រះរាជាណាចក្រកម្ពុជា ដែលមានដូចខាងក្រោម÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ប្រធាន |
| ២- ឯកឧត្តម **សុខ ចិន្តា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្តម **ទល្សី ទិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម **សួស គង់** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិកអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម **ជូ យិនស៊ីម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៦- ឯកឧត្តម **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧- ឯកឧត្តម **ម៉ុង សំផន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៨- ឯកឧត្តម **ទី ចន្ទ្រផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម **យិន គីមស៊ាន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១០- ឯកឧត្តម **ខិម គីមស៊ា** | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ១១- ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២- ឯកឧត្តម **ឈី លន់** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១៣- ឯកឧត្តម **ខុច ចនធីតូ** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤- ឯកឧត្តម **ឆេង គីមស៊ុន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **គីម ប៊ុនថាន** | នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងជានាយរងសេនាធិការចំរុះនៃអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ូ សាគុណា** | ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែននៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៧- ឯកឧត្តម **ហេង រតនា** | អគ្គនាយកមជ្ឈមណ្ឌលបោសសំអាតមីនកម្ពុជា | សមាជិក |
| ១៨- ឯកឧត្តម **អ៊ី ឈាន** | អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| ១៩- ឯកឧត្តម **អ៊ុំ ម៉ារ៉ា** | អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ | សមាជិក |

| | | |
|---|---|---|
| **២០- ឯកឧត្តម ស ថាវី** | អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| **២១- ឯកឧត្តម គោស៊ុំ សារឿន** | អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួង មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការរៀបចំ និងសម្របសម្រួលការអនុវត្តគោលនយោបាយ ផែនការ និងគម្រោងអភិវឌ្ឍការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង ក្នុងលក្ខណៈជាប្រព័ន្ធ និងជាខ្សែសង្វាក់ប្រទាក់ក្រឡាគ្នា។

គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម÷

- រៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍន៍ជាកញ្ចប់ សម្រាប់ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋនៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ឱ្យស្របតាម យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- រៀបចំគម្រោង និងជ្រើសរើសទីតាំងភូមិសាស្ត្រសមស្របសម្រាប់ធ្វើការអភិវឌ្ឍ នៅតាមបណ្តោយ ព្រំដែនទិសខាងលិច និងខាងជើង
- សម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ស្របតាមគោលនយោបាយ ផែនការ និងទីតាំងភូមិសាស្ត្រដែលបានជ្រើសរើស
- ផ្សព្វផ្សាយព័ត៌មាន ដើម្បីជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្ម័គ្រចិត្ត ទៅតាំងទីលំនៅនៅតំបន់ឱ្យបានច្រើនកុះករ
- ទាក់ទាញឱ្យមានការចូលរួមវិនិយោគពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅក្នុងការអនុវត្តគម្រោង។

**ប្រការ ៣.-**

គណៈកម្មការអន្តរក្រសួង ត្រូវធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងតំណាងដៃគូអភិវឌ្ឍន៍ ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៤.-**

គណៈកម្មការអន្តរក្រសួង ត្រូវមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។ ប្រធានគណៈកម្មការអន្តរក្រសួង អាចស្នើសុំមន្ត្រីពីក្រសួងស្ថាប័នពាក់ព័ន្ធឱ្យមកចូលរួមជាសមាជិកនៃលេខាធិការដ្ឋានតាមការចាំបាច់។

**ប្រការ ៥.-**

គណៈកម្មការអន្តរក្រសួងប្រើប្រាស់ត្រារបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសមាសភាពដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល÷</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និង ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០៨៩២ សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៣

# ប្រកាស
## ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ១០១៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងលិខិតលេខ៦២៧ សក.កឆ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ឆ្នាំង និងលិខិតលេខ២៧៨៥ កស.ហវ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១ :** ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ឆ្នាំង នៃក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកា ដូចមានបញ្ជាក់ខាងក្រោមនេះ៖

ឯកតា: ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ឆ្នាំ២០១៣ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | **និយ័តកម្មផ្ទៃក្នុងជំពូក 64** | **117.500** | **117.500** | **13.900** | **13.900** | **117.500** |
| 64 | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា | 34.600 | 34.600 | - | 13.900 | 20.700 |
| 64 | 644 | 6443 | បៀវត្សមូលដ្ឋានបុគ្គលិករណ្តែត | 72.000 | 72.000 | 13.000 | - | 85.000 |
| 64 | 645 | 6454 | ឧបត្ថម្ភនិវត្តជន | 10.900 | 10.900 | 900 | - | 11.800 |

**ប្រការ២ :** ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំង ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង
- រតនាគារខេត្តកំពង់ឆ្នាំង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៩៩ សហវ.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ , ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/១២១២/០១០ , ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦អនក្រ.បក , ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨សហវ.ប្រក , ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣
- យោងលិខិតលេខ២០៨៩ លស, ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ

## សម្រេច

**ប្រការ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកា ដូចមានបញ្ជាក់ខាងក្រោមនេះ ៖

ឯកតា: ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | **និយ័តកម្មផ្ទៃក្នុងជំពូក ៦១** | | | **180.000** | **180.000** | |
| 61 | 615 | 6158 | ការថែទាំ និងជួសជុលសម្ភារៈឧបករណ៍បច្ចេកទេស | 1.494.000 | 814.000 | - | 180.000 | 634.000 |
| 61 | 615 | 6156 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 900.000 | 900.000 | 180.000 | - | 1.080.000 |

**ប្រការ២:** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១១០០ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
# ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ,ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- យោងលិខិតលេខ ១២៦/១៣.បស្ថ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ របស់មន្ទីរបរិស្ថាន ខេត្តរតនគិរី និងលិខិតលេខ ៨៣០ ស.ណ ប.ស្ថ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ របស់ក្រសួងបរិស្ថាន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

**ប្រការ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកាបស់មន្ទីរបរិស្ថាន ខេត្តរតនគិរី នៃក្រសួងបរិស្ថានសម្រាប់ការគ្រប់គ្រង ថវិកាឆ្នាំ២០១៣នូវការធ្វើនិយ័តកម្មឥណទានថវិកាដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតា : ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ឥណទានដើមឆ្នាំ | ឥណទានបច្ចុប្បន្ន | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | ការធ្វើនិយ័តកម្មផ្ទៃក្នុងជំពូក ៦៤ | | | 8.500 | 8.500 | |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 92.000 | 92.000 | 8.300 | - | 100.300 |
| 64 | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | 2.000 | 2.000 | 200 | - | 2.200 |
| | | | - កូនមានអាយុតិចជាង១៥ឆ្នាំ | 800 | 800 | 170 | - | 970 |
| | | | - ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 1.200 | 1.200 | 30 | - | 1.230 |
| 64 | 645 | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន | 9.100 | 9.100 | - | 8.500 | 600 |

**ប្រការ២:** ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តមអភិបាលខេត្តរតនគិរីជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អូន_ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**
- អគ្គនាយកដ្ឋានរតនាគាររជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តរតនគិរី
- រតនាគារ ខេត្តរតនគិរី

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១១០១ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
# ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣,ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការ បែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងលិខិតលេខ ១១៦ វវស.ខបជ, ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបន្ទាយមានជ័យ និងចំណារបញ្ជូនលេខ ២៧៩ សណគហ, ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១** : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបន្ទាយមានជ័យ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រាប់ការគ្រប់គ្រងថវិកា ឆ្នាំ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកាផ្ទៃក្នុងជំពូកដូចមានបញ្ជាក់ខាងក្រោម៖

(ឯកតា:ពាន់រៀល)

